ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យ
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

---------

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ក្រោយពីបានដឹងថាស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ បានបង្ហោះសារអត្ថាធិប្បាយតែមួយជ្រុង លើរឿងក្តីរបស់លោក កឹម សុខា នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួន កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលបង្ហាញនូវចេតនាយ៉ាងច្បាស់ដើម្បីបំភាន់សាធារណៈមតិ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះទង្វើបែបនេះ ហើយចាត់ទុកកាយវិការនេះថា មិនមានលក្ខណៈការទូត និងមិនគោរពចំពោះអធិបតេយ្យភាពរបស់កម្ពុជា។ ក្រសួងការបរទេស ត្រូវបង្ខំចិត្តក្រើនរំលឹកដល់ស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ អំពីមាត្រា៤១នៃអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ដែលជាពិសេសតម្រូវឱ្យស្ថានទូតសហរដ្ឋអាមេរិក គោរពច្បាប់និងបទប្បញ្ញត្តិនានា និងមិនត្រូវជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាឡើយ។

ព្រះរាជាណាចក្រកម្ពុជា តែងតែគោរពអធិបតេយ្យភាពរបស់ប្រទេសដទៃ ហើយមិនដែលធ្វើអត្ថាធិប្បាយលើរឿងអាស្រូវគួរឱ្យខ្មាស់អៀនរបស់មន្ត្រីជាន់ខ្ពស់ និងអ្នកនយោបាយរបស់ប្រទេសណាមួយឡើយ។ ទង្វើក្នុងទិសដៅលំអៀងបែបនេះរបស់ស្ថានទូតសហរដ្ឋអាមេរិក គឺផ្ទុយទៅនឹងកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នរបស់ប្រទេសទាំងពីរ ក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងទ្វេភាគី ដែលបម្រើដល់ប្រយោជន៍រួមរបស់ប្រទេសនិងប្រជាជនទាំងពីរ។

ទន្ទឹមនឹងការទាមទារឱ្យស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ បញ្ឈប់ជាបន្ទាន់នូវសកម្មភាពដែលមានហេតុផលនយោបាយ និងគ្មានការទូតនេះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សូមបញ្ជាក់ឡើងវិញពីការប្តេជ្ញារបស់កម្ពុជាក្នុងការលើកកម្ពស់នីតិរដ្ឋ និងថែរក្សាសន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ដែលប្រជាជនកម្ពុជាកំពុងទទួលបាននាពេលបច្ចុប្បន្ន៕

ថ្ងៃ សៅរ៍ ១២កើត ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៩

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh